ការស្នើសុំសវនាការផ្លូវការ

ដើម្បីស្នើសុំសវនាការផ្លូវការ ផ្ញើសំបុត្រនូវព័ត៌មានខាងក្រោមក្នុងពេល 45 ថ្ងៃនៃការសម្រេចចិត្តដែលអ្នកកំពុងប្តឹងឧទ្ធរណ៍៖

Office of Administrative Hearings
PO Box 42489
Olympia, WA 98504-2489

សូមរាប់បញ្ចូលនូវ៖

- ឈ្មោះរបស់អ្នក អាសយដ្ឋាន និងលេខទូរស័ព្ទ
- សេចក្តីរំលឹងការណ៍ដាលាយលក្ខណ៍អក្សរដែលពន្យល់ពីអ្វីដែលអ្នកមិនយល់ព្រមជាមួយ និងមូលហេតុ
- ព័ត៌មានផ្សេងណាមួយដែលគាំទ្រដំហររបស់អ្នក (ឧ ច្បាប់ចម្លងនៃលិខិត DVR / សេចក្តីជូនដំណឹងពីសកម្មភាព)

សវនាការផ្លូវការគឺត្រូវបានធ្វើឡើងក្នុងពេល 60 ថ្ងៃនៃកាលបរិច្ឆេទដែលការស្នើសុំត្រូវបានទទួល។

ចំណាំ៖ សេវាកម្មជាមួយ DVR របស់អ្នកបន្ត ខណៈពេលបញ្ហាស្ថិតក្រោមការត្រួតពិនិត្យឡើងវិញ លុះត្រាតែមានភស្តុតាងដែលអ្នកបានទទួលសេវា DVR ដោយផ្តល់ព័ត៌មានមិនពិត ការលួចបន្ទំដែលបានប្តេជ្ញាចិត្ត ឬអំពើខុសច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធនឹងសេវា DVR។

បើសិនអ្នកសម្រេចចិត្តស្នើសុំសវនាការផ្លូវការ អ្នកនៅតែអាចព្យាយាមដោះស្រាយបញ្ហាដោយក្រៅផ្លូវការ។ បើសិនអ្នកឈានដល់កិច្ចព្រមព្រៀងជាមួយ DVR មុនពេលសវនាការ អ្នកត្រូវតែជូនដំណឹងដល់ការិយាល័យរដ្ឋបាលសវនាការ ដើម្បីបោះបង់សវនាការនោះ។

បុគ្គលិក DVR ទាំងឡាយអាចផ្តល់នូវព័ត៌មានបន្ថែមអំពីជម្រើសទាំងនេះ រួមមានទាំងព័ត៌មានទំនាក់ទំនងសម្រាប់ OAH។

“ ខ្ញុំបានកោតសរសើរដល់ឱកាសចូលរួមក្នុងការសម្រុះសម្រួលផ្លូវការ ពីព្រោះវាបានធ្វើឡើងជាមួយការទាក់ទង និងការយល់ដឹងពីជំហរ និងក្តីកង្វល់របស់អ្នកផ្សេង។ ”

Division of Vocational Rehabilitation
Washington State Department of
Social and Health Services
PO Box 45340 ▪ Olympia, WA 98504-5340
1-800-637-5627 ឬ (360) 725-3636
លេខបញ្ជូនបន្តវ៉ាស៊ីនតោន៖ 711

www.dshs.wa.gov/ra/division-vocational-rehabilitation

DSHS 22-824 CA (Rev. 9/16) Cambodian

ជនពិការ

សិទ្ធិរបស់អ្នកជាអតិថិជន DVR

Washington State Department of Social & Health Services
Transforming lives

ទាយកដ្ឋានស្តារនីតិសម្បទាវិជ្ជាជីវៈ

បើសិនអ្នក និងអ្នកផ្តល់ប្រឹក្សា DVR របស់អ្នកមានបញ្ហាក្នុងការឈានដល់កិច្ចព្រមព្រៀងលើការសម្រេចចិត្តមួយ ជម្រើសខាងក្រោមអាចប្រើបានសម្រាប់អ្នក៖

1 ពិភាក្សាជាមួយអ្នកផ្តល់ប្រឹក្សា DVR របស់អ្នក

ពន្យល់ពីហេតុផលសម្រាប់ការសម្រេចចិត្តរបស់អ្នក និងចែករំលែកព័ត៌មានដែលគាំទ្រជំហររបស់អ្នក។ បន្ទាប់ពីនិយាយអំពីបញ្ហា បើសិនអ្នក និងអ្នកផ្តល់ប្រឹក្សា DVR របស់អ្នកនៅតែមិនយល់ព្រម អ្នកអាចនិយាយទៅកាន់ប្រធានរបស់ពួកគេ ហើយស្នើសុំឱ្យត្រួតពិនិត្យការសម្រេចចិត្តឡើងវិញ។

2 ស្វែងរកជំនួយពីកម្មវិធីជំនួយអតិថិជន (CAP)

កម្មវិធីជំនួយអតិថិជន (CAP) គឺជាកម្មវិធីឯករាជ្យដែលបានបង្កើតឡើងនៅក្រោមច្បាប់ ដើម្បីផ្តល់ជំនួយ និងព័ត៌មានអំពីសិទ្ធិរបស់អ្នកជាអតិថិជន DVR ដោយមិនគិតថ្លៃពីអ្នក។ អ្នកទទួលការស្វាគមន៍ឱ្យទាក់ទង CAP គ្រប់ពេលអំឡុងដំណើរការស្តារនីតិសម្បទាវិជ្ជាជីវៈ។ អ្នកតំណាង CAP អាចជួយឱ្យអ្នកយល់ និងទទួលបានសេវាដែលអាចរកបានពី DVR ឬអាចជួយអ្នកពិភាក្សាជាមួយ DVR អំពីក្តីកង្វល់របស់អ្នក។

ដើម្បីទាក់ទងអ្នកតំណាងពី CAP ទូរស័ព្ទទៅលេខ 206-721-5999 ឬ 1-800-544-2121 ជាសំឡេង 206-721-6072 TTY។ គេហទំព័រនៅ **www.washingtoncap.org** របស់ CAP ក៏មានព័ត៌មានទំនាក់ទំនងបុគ្គលិក និងការរៀបរាប់ពីកម្មវិធី CAP។

3 ប្រគល់សំណើជាលាយលក្ខណ៍អក្សរសម្រាប់ករណីលើកលែងលើគោលនយោបាយ

អ្នកអាចស្នើសុំករណីលើកលែងលើគោលនយោបាយពីប្រធានអ្នកផ្តល់ប្រឹក្សា DVR របស់អ្នក។ សំណើរបស់អ្នកគួរតែជាលាយលក្ខណ៍អក្សរ និងរួមមាន៖ ការរៀបរាប់ពីករណីលើកលែងដែលកំពុងត្រូវបានស្នើសុំ ហេតុផលដែលអ្នកកំពុងស្នើសុំករណីលើកលែងនេះ និងរយៈពេលនៃការលើកលែង។ ប្រធាន DVR នឹងពិនិត្យការស្នើសុំនេះឡើងវិញ ហើយឆ្លើយតបជាលាយលក្ខណ៍ជាមួយនឹងការពន្យល់ពីហេតុផលសម្រាប់ការអនុម័ត ឬការបដិសេធ។ អ្នកអាចស្នើសុំជំនួយពីអ្នកផ្តល់ប្រឹក្សា DVR របស់អ្នក ឬបុគ្គលិក VR ផ្សេង ដើម្បីបំពេញសំណើជាលាយលក្ខណ៍អក្សរសម្រាប់ករណីលើកលែងលើគោលនយោបាយ។

4 ស្នើសុំការសម្រុះសម្រួល

ការសម្រុះសម្រួលគឺជាជម្រើសផ្សេងដែលអ្នកអាចស្នើសុំ បើសិនអ្នកមិនយល់ព្រមតាមការសម្រេចចិត្តដែល DVR ធ្វើ។ ការសម្រុះសម្រួលគឺជាដំណើរការស្ម័គ្រចិត្ត ហើយទាំងអ្នក និង DVR ត្រូវតែយល់ព្រមតាមការសម្រុះសម្រួល។

DVR ផ្តួលអ្នកសម្រុះសម្រួលខាងក្រៅឱ្យមកជួបជាមួយអ្នក និងអ្នកតំណាង DVR ដែលជាធម្មតាអ្នកផ្តល់ប្រឹក្សារបស់អ្នក។ ទាំងអ្នក និង DVR នឹងមានឱកាសពន្យល់ហេតុផលសម្រាប់ការសម្រេចចិត្តរបស់អ្នក និងចែករំលែកព័ត៌មានណាមួយដែលគាំទ្រជំហររបស់អ្នក។ តួនាទីរបស់អ្នកសម្រុះសម្រួលគឺដើម្បីជួយអ្នក និង DVR និយាយអំពីបញ្ហា និងឈានដល់កិច្ចព្រមព្រៀងទៅវិញទៅមក។

បើសិនអ្នកសម្រុះសម្រួលមិនមានលទ្ធផលដល់កិច្ចព្រមព្រៀងមួយទេ អ្នកនៅតែមានសិទ្ធិស្នើសុំសវនាការផ្លូវការ ឬប្រើជម្រើសផ្សេង។ សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីស្នើសុំការសម្រុះសម្រួល និយាយទៅអ្នកផ្តល់ប្រឹក្សា DVR របស់អ្នក ឬបុគ្គលិក DVR ផ្សេងទៀត ឬទូរស័ព្ទ 1-800-637-5627 (V/TTY) ដើម្បីនិយាយអ្នកតំណាងសេវាអតិថិជន DVR។

5 ស្នើសុំសវនាការផ្លូវការ

អ្នកអាចរំលងជម្រើសក្រៅផ្លូវការដែលបានធ្វើកម្រោងខាងលើ ហើយស្នើសុំសវនាការផ្លូវការមួយគ្រប់ពេលដែលអ្នកមិនយល់ព្រមជាមួយការសម្រេចចិត្តដែល DVR ធ្វើ។

អំឡុងពេលសវនាការផ្លូវការ ទាំងអ្នក និង DVR អាចបង្ហាញព័ត៌មាន សាក្សី និងឯកសារដើម្បីគាំទ្រជំហររបស់អ្នក។ អ្នកអាចស្នើសុំមេធាវី ឬមនុស្សផ្សេងទៀតតំណាងឱ្យអ្នក ក្នុងការចំណាយផ្ទាល់ខ្លួនរបស់អ្នក បើអ្នកជ្រើសរើស។ ចៅក្រមច្បាប់រដ្ឋបាលធ្វើការសម្រេចចិត្ត បន្ទាប់ពីពិចារណារលើព័ត៌មាន និងឯកសារណាមួយដែលបានបង្ហាញ។

ការិយាល័យរដ្ឋបាលសវនាការ (OAH) ធ្វើការសម្រេចចិត្តជាលាយលក្ខណ៍អក្សរទៅអ្នកក្នុងពេល 30 ថ្ងៃនៃសវនាការផ្លូវការ។ ការសម្រេចចិត្តសវនាការគឺជាស្ថាពរ ហើយ DVR អនុវត្តការសម្រេចចិត្តនោះ។

សិទ្ធិអតិថិជន

នៅ DVR យើងចង់ឃើញអតិថិជនរបស់យើងទាំងអស់ឈានដល់គោលដៅការងាររបស់ពួកគេ។ ក្នុងនាមជាអតិថិជន DVR អ្នកធ្វើការសម្រេចចិត្តអំពីគោលដៅការងារ និងសេវាកម្មនានារបស់អ្នកក្នុងភាពជាដៃគូជាមួយអ្នកផ្តល់ប្រឹក្សា DVR។ វាមានសារៈសំខាន់សម្រាប់អ្នកដែលត្រូវដឹងពីសិទ្ធិរបស់អ្នកនៅទូទាំងដំណើរការស្តារនីតិសម្បទានៅពេលធ្វើការសម្រេចចិត្តសំខាន់ៗទាំងនេះ។